CCOC

# 105, St. 105 & 350
Sangkat Boeung Keng
Kang 3, Khan Chamì Car
Mon, P Penh
Tel : (855-23) 982 851

**គណៈកម្មាធិការសម្របសម្រួលកម្ពុជា**

**សម្ព័ន្ធអង្គការ-សមាគម មិនមែនរដ្ឋាភិបាល**

**CAMBODIA CO-ORDINATION COMMITTEE**

**LEAQUE OF NON-GOVERNMENT ORGANIZATION**

គ.ស.ក CCOC

# សេចក្តីថ្លែងការណ៍

## របស់គណៈកម្មាធិការសម្របសម្រួលកម្ពុជា

*************

**-សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃរាជទាំងពីរគណៈព្រមទាំងព្រះសង្ឃគ្រប់ព្រះអង្គជាទីសក្ការៈ !**

**-សូមគោរពបងប្អូនជនរួមជាតិជាទីគោរព !**

គណៈកម្មាធិការសម្របសម្រួលកម្ពុជា-ស៊ីកុក ដែលមានអង្គការ-សមាគមខ្មែរក្រៅរដ្ឋាភិបាល ចំនួន ៧០ជាសមាជិក និង ដែលជាក្រុមអ្នក សង្កេតការណ៍ជាតិនៅក្នុងការបោះឆ្នោតនៅឆ្នាំ១៩៩៨នេះ ដោយមានការទទួលស្គាល់ ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមរយៈលិខិតលេខ ០៥_៨០៨.៩៨ គ.ជ.ប ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៩៨ និង លិខិតលេខ៣១៧.៩៨ អ.គ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨ សូមធ្វើសេចក្តីថ្លែងការណ៍ ប្រគេន និង ជូនសម្តេចព្រះសង្ឃរាជ ព្រះសង្ឃគ្រប់ព្រះអង្គ និង ជនរួមជាតិ ជ្រាបអំពីស្ថានការណ៍ទូទៅដែលពាក់ព័ន្ធដល់ការបោះឆ្នោត ឆ្នាំ១៩៩៨ នេះដូចតទៅ :

ក្នុងឋានៈជាក្រុមអ្នកសង្កេតការណ៍ជាតិ និង ដោយផ្អែកលើរបាយការណ៍របស់សមាជិកក្រុមអ្នកសង្កេតការណ៍យើងនៅទូទាំងប្រទេសបានសង្កេតឃើញថា ចាប់តាំងពីមុនដំណើរការរៀបចំការបោះឆ្នោតផ្តើមធ្វើឡើងម្ល៉េះ ក្រុមអ្នកនយោបាយមួយចំនួនដែលមិនគោរពសុឆន្ទៈចង់បានសន្តិភាព ប្រជាធិបតេយ្យ និង ការអភិវឌ្ឍន៍ប្រទេសជាតិរបស់ប្រជារាស្ត្រខ្មែរទូទាំងប្រទេសបានព្យាយាមបំផ្លិចបំផ្លាញ និង ធ្វើអោយរាំងស្ទះដល់ដំណើរការបោះឆ្នោតនេះ ដោយមានបំណងធ្វើពហិការ មិនចូលរួមក្នុងការបោះឆ្នោត និង សុំពន្យាពេលការបោះឆ្នោត ។ល។ ក៏ប៉ុន្តែការបោះឆ្នោតនេះ ត្រូវធ្វើឡើងសំរាប់ប្រជារាស្ត្រខ្មែររាប់លាននាក់គឺ មិនមែនសំរាប់តែក្រុមអ្នកនយោបាយមួយចំនួនតូចនេះប៉ុណ្ណោះទេ ហើយការពន្យាពេលនៃការបោះឆ្នោតនេះទៀតសោត ក៏មិនអាចធ្វើទៅបាន ពីព្រោះបើផុតពីខែកក្កដានេះទៅគឺ ជារដូវភ្លៀងធ្លាក់ខ្លាំង ដែលប្រជារាស្ត្រខ្មែរភាគច្រើនជាកសិករជាប់រវល់ការងារស្រែចំការរបស់គាត់ និង ប្រជារាស្ត្រខ្មែរមួយចំនួនទៀតដែលជាចាស់ជរា អ្នកពិការ អ្នកជំងឺ អ្នកមានកូនខ្ចី មានការលំបាកមិនអាចចូលរួមការបោះឆ្នោតបានពីនោះទៀតដោយពួកគេមិនអាចប្រឆាំងបាននូវសុឆន្ទៈប្រជារាស្ត្រទើបក្រុមអ្នកនយោបាយទាំងនោះគ្មានលេស អ្វីសំរាប់ប្រឆាំងទល់ នឹងសភាពជាក់ស្តែងខាងលើ ក៏យល់ព្រមចូលរួមក្នុងដំណើរការបោះឆ្នោត ។

នៅក្នុងលិខិតមួយច្បាប់ផ្ញើរជូន ឯកឧត្តម **កូហ្វី អានណាន់** អគ្គលេខាធិការអង្គការសហប្រជាជាតិ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីអំពីស្ថានភាពទូទៅនៃដំណើរការបោះឆ្នោតឆ្នាំ១៩៩៨ នៅកម្ពុជា គណៈកម្មាធិការសម្របសម្រួលកម្ពុជាស៊ីកុក បានគូសបញ្ជាក់ជូន ឯកឧត្តមអគ្គលេខាធិការជ្រាបថា ទោះបីក្រុមអ្នកនយោបាយទាំងនេះគ្មានលេសអ្វីសំរាប់គេចចេញពីការបោះឆ្នោតយ៉ាងនេះក៏ដោយ ក៏គេនៅតែគ្មានបានបង្ហាញអោយឃើញនូវសុឆន្ទៈពិតប្រាកដណាមួយរបស់ខ្លួន ក្នុងការចូលរួមក្នុងដំណើរការបោះឆ្នោតនេះជាដដែលពោលគឺ គេបានព្យាយាមតាមគ្រប់មធ្យោបាយ ដើម្បីធ្វើអោយអន្តរាយដល់ដំណើរការបោះឆ្នោតដោយការប្រមូលយកករណីប្លន់ប្រដាប់អាវុធ និង ករណីឃាតកម្មធម្មតា ដែលបណ្តាលមកពីជំលោះស្រី ស្រា ល្បែង ឬ ដីធ្លី ផ្ទាល់ខ្លួនមកធ្វើជាលេស ដើម្បីទំលាក់កំហុសលើរឿងនយោបាយ ដែលពាក់ព័ន្ធដល់ ដំណើរការបោះឆ្នោត ។

**សម្តេចព្រះសង្ឃរាជ ព្រះសង្ឃគ្រប់ព្រះអង្គ និង ជនរួមជាតិជាទីគោរព !**

ក្រៅអំពីកល្បិចខ្មៅកខ្វក់ដូចខាងលើនេះ ក្រុមអ្នកនយោបាយទាំងនោះ បានប្រើប្រាស់ពាក្យពេចន៍ ឃោសនាញុះញង់ក្នុងគោលបំណងបង្កអោយកើនមានអំពើឃោរឃៅនៅក្នុងយុទ្ធនាការឃោសនាជាច្រើន ដូចជាគេបានជេរប្រមាថរំលោភលើក្រមសីល-ធម៌របស់គណបក្សនយោបាយទៅលើគណបក្សផ្សេងៗទៀតទៅលើមន្ត្រីរាជការ និង ទៅលើអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ដើម្បីអោយមានការតបតសំរាប់យកលេសបំផ្លិចបំផ្លាញដល់ដំណើរការបោះឆ្នោត ។

ឆ្លងកាត់តាមសភាពការណ៍ជាក់ស្តែងដូចបានរៀបរាប់ប្រគេន និង ជំរាបជូនមកខាងលើនេះ ឆ្លុះបញ្ចាំងអោយឃើញថា គណបក្សមួយចំនួន តូចនេះគ្មានសុឆន្ទៈពិតប្រាកដក្នុងការចូលរួមក្នុងដំណើរការបោះឆ្នោតនេះទេ ពីព្រោះគេបានដឹងរួចជាស្រេចទៅហើយថា គណបក្សរបស់គេប្រាកដជាចាញ់នៅក្នុងការបោះឆ្នោតនេះជាមិនខាន ហើយគេបានត្រៀមខ្លួនរួចជាស្រេច ដើម្បីទាត់ចោលនូវលទ្ធផលនៃការបោះឆ្នោតជាចុងក្រោយនេះ បើទោះបីជាមតិសាធារណៈជាតិ និង អន្តរជាតិបានចាត់ទុកថា ជាការអាចទទួលយកបាននូវលទ្ធផលនៃការបោះឆ្នោតនេះយ៉ាងណាក៏ដោយ បានតវ៉ាទទឹងឡាំប៉ាចុងក្រោយរបស់គណបក្សនយោបាយមួយចំនួនដ៏តិចតួចពីលទ្ធផលបោះឆ្នោតដែលមិនត្រឹមត្រូវនឹងយុត្តិធម៌នោះ ជាលេសក្នុងល្បែងល្បិចកលដ៏ពិសពុលរបស់ពួកគេ ក្នុងមហិច្ឆតាអំណាច នឹងពួកបំផ្លាញសង្គមជាតិប៉ុណ្ណោះហើយពួកគេ ក៏កំពុងប្រមាថមើលងាយដល់ប្រជារាស្ត្រខ្មែរទូទៅជាម្ចាស់ឆ្នោតផងដែរ ដែលធ្វើឱ្យប្រជារាស្ត្រខ្មែរស្អប់ខ្ពើមហើយមិនអាចទទួលយកបាននោះឡើយ ។

នៅទីបញ្ចប់នៃសេចក្តីថ្លែងការណ៍នេះ គណៈកម្មាធិការសម្របសម្រួលកម្ពុជា សូមថ្លែងនូវសេចក្តីកោតសរសើរដោយស្មោះ ចំពោះគណបក្សនយោបាយធំមួយ ដែលកំពុងកាន់អំណាចរាជរដ្ឋាភិបាល និង អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលបានអត់ធ្មត់គ្រប់បែបយ៉ាង ដើម្បីបង្កលក្ខណៈអោយការបោះឆ្នោតបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ ដែលការនេះសបញ្ជាក់អោយឃើញនូវស្មារតីគោរពឆន្ទៈប្រជារាស្ត្រខ្មែរដែលចង់បានសន្តិភាព លទ្ធិប្រជាធិបតេយ្យនិងការអភិវឌ្ឍន៍ប្រទេសជាតិយ៉ាងពិតប្រាកដនោះ ។

សូមសម្តែងសេចក្តីកោតសរសើរ ចំពោះគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានខិតខំប្រឹងប្រែងព្យាយាមជំរុញដំណើរការបោះ ឆ្នោតអោយប្រព្រឹត្តិទៅបាន ប្រកបដោយជោគជ័យ និង តាមពេលកំណត់ ។

សូមសម្តែងសេចក្តីកោតសរសើរផងដែរ ចំពោះក្រុមអ្នកសង្កេតការណ៍រួមរបស់អន្តរជាតិ ដែលបានខិតខំបំពេញការងាររបស់ខ្លួនយ៉ាងមមាញឹកហើយបានចេញនូវសេចក្តីថ្លែងការណ៍បញ្ជាក់ថា ការបោះឆ្នោតបានប្រព្រឹត្តិទៅប្រកបដោយលក្ខណៈប្រជាធិបតេយ្យ សេរីត្រឹមត្រូវ និង យុត្តិធម៌ ដែលអាចទទួលយកបានហើយប្រសើរជាងការបោះឆ្នោតដែលបានរៀបចំឡើងដោយ **UNTAC** កាលពីឆ្នាំ១៩៩៣ នោះទៅទៀត ។

គណៈកម្មាធិការសម្របសម្រួលកម្ពុជា( ស៊ីកុក) សូមអំពាវនាវផងដែរចំពោះគណបក្សនយោបាយទាំងអស់ សូមគោរពនូវសច្ចៈភាព ទទួលស្គាល់នូវលទ្ធផលនៃការបោះឆ្នោត ដ៏ត្រឹមត្រូវ និង យុត្តិធម៌នេះដើម្បីនាំមកនូវសុខសន្តិភាពជូនប្រជារាស្ត្រខ្មែរទូទាំងប្រទេស ។

*ធ្វើនៅភ្នំពេញថ្ងៃទី១ ខែសីហា ឆ្នាំ១៩៩៨*

ជ.គណៈកម្មាធិការសម្របសម្រួលកម្ពុជា

**ប្រធានស្តីទី**

CAMBODIA COORDINATION COMMITTEE
CCOC

**ទៅ ឬី**